**ព្រះរាជាណាចក្រកម្ពុជា**

ជាតិ សាសនា ព្រះមហាក្សត្រ

**ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ**

**លេខ** :..........០៣០/១៨..........ក.ប/ស.រ.ណ.ភ.ភ.ស

# សេចក្តីជូនដំណឹង

## ស្តីពីការជ្រើសរើសសិស្ស-និស្សិតអាហារូបករណ៍ថ្នាក់សញ្ញាបត្រជាន់ខ្ពស់បច្ចេកទេស (Diploma) ទៅសិក្សានៅប្រទេសចិន ក្នុងឆ្នាំសិក្សា២០១៨-២០១៩

**យោង៖** លិខិតលេខ BEIIE/2018(1011) ចុះថ្ងៃទី១៤ ខែសីហា ឆ្នាំ២០១៨ របស់ Beijing Education Institute for International Exchanges (BEIIE) នៃប្រទេសចិន។

ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ សូមជូនដំណឹងដល់សាធារណជនទាំងអស់ មេត្តាជ្រាបថា ក្នុងឆ្នាំ២០១៨ នេះ Beijing Education Institute for International Exchanges (BEIIE) នៃប្រទេសចិន បានផ្តល់អាហារូបករណ៍ចំនួន **២៧៥កន្លែង** កម្រិតសញ្ញាបត្រជាន់ខ្ពស់បច្ចេកទេស (Diploma) ដល់សិស្ស-និស្សិតកម្ពុជា សិក្សារយៈពេល **០៣ឆ្នាំ** លើមុខជំនាញអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ នៅតាមគ្រឹះស្ថានសិក្សានៃប្រទេសចិនចំនួន ១១ (ដូចមានជូនភ្ជាប់) ។ ភាគីចិនទទួលរ៉ាប់រងលើថ្លៃសិក្សា និងការស្នាក់នៅ រីឯការចំណាយផ្សេងៗទៀត ជាបន្ទុករបស់សាមីជន។

**១-<u>លក្ខខណ្ឌនៃការជ្រើសរើស</u>**

បេក្ខជនទាំងពីរភេទត្រូវ៖

- មានសញ្ជាតិខ្មែរ
- មានអាយុចាប់ពី ១៨ឆ្នាំឡើងទៅ
- ជាសិស្សជាប់ ឬធ្លាក់សញ្ញាបត្រមធ្យមសិក្សាទុតិយភូមិ(បាក់ឌុប)
- មានចំណេះដឹងផ្នែកភាសាចិន និងអង់គ្លេស
- សិក្សារយៈពេល ៣ឆ្នាំ

**២-<u>ឯកសារដែលត្រូវបំពេញ និងជូនភ្ជាប់</u>**

- ពាក្យស្នើសុំអាហារូបករណ៍ (Application Form )
- លិខិតឆ្លងដែន (មានសុពលភាព)
- ព្រឹត្តិបត្រពិន្ទុ

អាសយដ្ឋាន អគារលេខ៣ មហាវិថីសហព័ន្ធរុស្ស៊ី សង្កាត់ទឹកល្អក់១ ខណ្ឌទួលគោក ទូរស័ព្ទ:(០២៣) ៨៨ ៤៣ ៧៥ និងទូរសារ :(០២៣)៨៨ ២៧ ៦៩

- សញ្ញាបត្រមធ្យមសិក្សាទុតិយភូមិ ឬវិញ្ញាបនបត្របញ្ចប់ការសិក្សាថ្នាក់ទី១២ (បកប្រែជាភាសាអង់គ្លេស)
- លិខិតបញ្ជាក់សុខភាព (បញ្ជាក់ដោយនាយកដ្ឋានពេទ្យការងារ)
- លិខិតថ្កោលទោស

៣-ទីកន្លែង និងកាលបរិច្ឆេទទទួលពាក្យ

បេក្ខជនដែលមានបំណងចូលរួមកម្មវិធីអាហារូបករណ៍ខាងលើ សូមទំនាក់ទំនងការិយាល័យទំនាក់ទំនង និងអាហារូបករណ៍ នៃនាយកដ្ឋានគ្រប់គ្រងគ្រឹះស្ថានសិក្សា អគារលេខ៣ មហាវិថីសហព័ន្ធរុស្ស៊ី សង្កាត់ទឹកល្អក់១ ខណ្ឌទួលគោក រាជធានីភ្នំពេញ ដើម្បីស្នើសុំ និងដាក់ពាក្យស្នើសុំអាហារូបករណ៍ និងសំណុំបែបបទផ្សេងៗ ចាប់ពីថ្ងៃផ្សាយដំណឹងនេះតទៅ រហូតដល់ថ្ងៃទី១៥ ខែកញ្ញា ឆ្នាំ២០១៨។

*សម្រាប់ព័ត៌មានបន្ថែម៖*

*-ទូរស័ព្ទលេខ៖ ០១៥ ៦៨៨ ៨៤៧ / ០១៧ ៩៤៣ ៨២៤*

*-សារអេឡិចត្រូនិក៖ nhim_sokny@yahoo.com*

ថ្ងៃ ព្រហស្បតិ៍ ៤រោច ខែ ស្រាពណ៍ ឆ្នាំច សំរឹទ្ធិស័ក ព.ស.២៥៦២

រាជធានីភ្នំពេញ ថ្ងៃទី ៣០ ខែ សីហា ឆ្នាំ២០១៨

**រដ្ឋមន្ត្រី**

**អ៊ិត សំហេង**

**ចម្លងជូន៖**

- អគ្គនាយកដ្ឋានអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ
- អគ្គនាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ
- មន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
- អង្គភាពពាក់ព័ន្ធ "ដើម្បីជូនជ្រាប"
- ឯកសារ-កាលប្បវត្តិ